ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧០ សហវ.ប្រ.ក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់ និង កែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ ជូនកូនរបស់គ្រួសារជនពលី និង មរណៈ

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០២/១២៤, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១, ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក, ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋាន មួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបឧបត្ថម្ភ ចំពោះយោធិនពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និង ពិការ
- បានឃើញសេចក្តីសម្រេច ២០ សសរ, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយ ចំពោះជនពលី ពិការ និង លិខិតលេខ ៥១៥ សជណ អវ.ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩១ របស់រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី
- យោងមតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៧
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ លើលិខិតលេខ ២៩៩ សហវ.ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

Downloaded from http://www.khmerlaws.com

# ស ម្រេ ច

**ប្រការ ១ :** ត្រូវបានតំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ ជូនកូនគ្រួសារជនពលី និង មរណៈរបស់អតីតយោធិន នៃកងយោធពលខេមរភូមិន្ទ និង កងកម្លាំងនគរបាលជាតិ ពី ៤.០០០ រៀល (បួនពាន់រៀល) ទៅ ៨.០០០ រៀល (ប្រាំបីពាន់រៀល) សំរាប់កូនម្នាក់ ។

**ប្រការ ២ :** បទបញ្ញត្តិណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រការ ១ ខាងលើ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ នេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ មីនា ឆ្នាំ ២០០៧

**នេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង ដើម្បីអនុវត្ត
- ឯកសារ និង កាលប្បវត្តិ

Downloaded from http://www.khmerlaws.com